# សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ**

ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណង
សម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន

០៤ មិនា ២០១៦

- **សូមគោរព លោកស្រី MATSUURA AYUMI នាយិកាអង្គការ IVY!**
- **សូមគោរព អស់លោក លោកស្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាខ្លាំងដែលបានមកចូលរួមចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ ជូនដល់អង្គការអាយ.វី.វ៉ាយ សម្រាប់គម្រោងកាត់បន្ថយភាពក្រីក្រ តាមរយៈការពង្រឹងទីផ្សារនៃផលិតផលសរីរាង្គរបស់សហគមន៍កសិកម្មក្នុងខេត្តចំនួន២ "ដំណាក់កាលទី១"។

រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យស្តីអំពីការបង្កើត និងការប្រព្រឹត្តទៅនៃសហគមន៍កសិកម្មក្នុងឆ្នាំ២០០១ និងបានបង្កើតច្បាប់សហគមន៍កសិកម្មនៅក្នុងឆ្នាំ២០១៣ ដើម្បីជំរុញការបង្កើតឡើងរបស់សមាគមន៍កសិករ។ ក៏ប៉ុន្តែខ្ញុំបានទទួលដំណឹងថាគម្រោងសេដ្ឋកិច្ចដូចជា ការបង្កើតនិងដាក់លក់ក្នុងទីផ្សាររួមគ្នាដើម្បីលើកស្ទួយចំណូលរបស់ប្រជាកសិករក្រីក្រ នៅមិនទាន់មានការដំណើរការទៅមុខប្រសើរនោះទេ។

ស្ថិតក្នុងស្ថានភាពនេះ អង្គការអាយ.វី.វ៉ាយ បាននឹងកំពុងបន្តសកម្មភាពរបស់ខ្លួនអស់រយៈពេល ១៧ឆ្នាំមកហើយចាប់តាំងពីឆ្នាំ១៩៩៩ ក្រោមជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន និងការប្រើប្រាស់គម្រោងរបស់អង្គការJICA នៅក្នុងខេត្តស្វាយរៀង ដើម្បីជួយបង្កើតសហគមន៍កសិកម្ម កែលម្អសមត្ថភាពគ្រប់គ្រងសហគមន៍អោយកាន់តែល្អប្រសើរ និងពង្រឹងប្រព័ន្ធទីផ្សារក៏ដូចជាផលិតភាពរបស់សហគមន៍កសិកម្មជាដើម។ បច្ចុប្បន្នសហគមន៍កសិកម្មអាចដាក់លក់បន្លែរបស់ខ្លួនជាច្រើននៅក្នុងផ្សារទំនើប នៅរាជធានីភ្នំពេញ ហើយនេះ មិនត្រឹមតែជួយដល់ការលើកស្ទួយជីវភាពរស់នៅរបស់ប្រជាកសិករនោះទេ តែក៏បានរួមចំណែកក្នុងការផ្គត់ផ្គង់បន្លែជាច្រើននៅកម្ពុជាផងដែរ ។

នៅក្នុងគម្រោងនេះ រដ្ឋាភិបាលជប៉ុន នឹងផ្តល់ជូនថវិកាប្រមាណជា ៣៤ម៉ឺនដុល្លារអាមេរិក ហើយអង្គការអាយ.វី.វ៉ាយ នឹងចាប់ផ្តើមបន្តសកម្មភាពរបស់ខ្លួននៅក្នុងខេត្តព្រះវិហារ ជាមួយនឹងចំណេះដឹង និងបទពិសោធន៍កន្លងដែលបានអនុវត្តនៅក្នុងខេត្តស្វាយរៀង។ នៅក្នុងខេត្តព្រះវិហារ ជាទំលាប់កសិករដាំដុះស្រូវដោយប្រើវិធីសាស្ត្រសរីរាង្គ ហើយបច្ចុប្បន្នកសិករបានរួបរួមគ្នាបង្កើតជាសហគមន៍ផ្គត់ផ្គង់ស្រូវសរីរាង្គចំនួន៨។ គម្រោងនេះ នឹងបង្កើតសហគមន៍កសិកម្មចំនួន៤បន្ថែមទៀត ហើយអង្គការនឹងជួយបង្រៀនពីបច្ចេកទេសគ្រប់គ្រងទៅដល់សហគមន៍កសិករទាំង១២សហគមន៍ ហើយនឹងជំរុញហើយមាន

ទីផ្សាររួមគ្នាមួយសម្រាប់ដាក់លក់ស្រូវសរីរាង្គ ដើម្បីជួយធ្វើអោយប្រសើរឡើងនូវជីវភាពរស់នៅរបស់កសិករនៅក្នុងខេត្តព្រះវិហារ។

ឥឡូវសហគមន៍ផ្គត់ផ្គង់កសិផលខេត្តស្វាយរៀង អាចផ្គត់ផ្គង់បន្លែជាមធ្យមបានចំនួន៩តោនក្នុងមួយខែ ហើយគម្រោងនេះ នឹងធ្វើការសាងសង់នូវមជ្ឈមណ្ឌលទីផ្សារសហគមន៍ថ្មីមួយផងដែរ។ បើទោះបីជាគម្រោងនេះត្រូវបានបញ្ចប់ តែខ្ញុំសង្ឃឹមថា សកម្មភាពរបស់សហគមន៍កសិកម្មនេះនឹងនៅតែបន្តការដាក់លក់បន្លែ ហើយនឹងក្លាយជាគំរូមួយដ៏ល្អមិនមែនសម្រាប់តែខេត្តនេះតែប៉ុណ្ណោះទេ តែក៏សម្រាប់ខេត្តដ៏ទៃទៀតផងដែរ។

ជាទីបញ្ចប់ ជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ត្រូវបានផ្តល់ជូនអង្គការក្រៅរដ្ឋាភិបាលជប៉ុនសម្រាប់គម្រោងអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចដែលផ្តល់អត្ថប្រយោជន៍ដល់ប្រជាជននៅកម្រិតមូលដ្ឋាន។ ខ្ញុំសង្ឃឹមថាគម្រោងដែលចុះហត្ថលេខានៅថ្ងៃនេះ នឹងរួមចំណែកជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណ!**